មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ ធី អូច ភេទស្រី អាយុ៥៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ“សេដ្ឋកិច្ច”**

**ស្រុកកំណើតនៅភូមិកោះមីយើល ឃុំកោះញែក ស្រុកកោះញែក ខេត្តមណ្ឌលគិរី**

**រស់នៅភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០០:៥១:១៥**

**២៥ទំព័រ**

វណ្ណៈ៖ ចឹងថ្ងៃទី២០ខែ១២ឆ្នាំ២០១៣ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានមកដល់ភូមិឃុំមីងចឹងដឹងរឿងរ៉ាវ ដែលទាក់ទងនិងសម័យកាលកន្លងមក ចឹងចាំមីងជួយឆ្លើយឲ្យបានល្អបន្តិច ចឹងបទសម្ភាសខ្ញុំជាមួយមីងហ្នឹង ខ្ញុំចង់យកទៅសរសេរជាសៀវភៅ ដើម្បីឲ្យក្មេងៗបានដឹងល្អពីប្រវត្តិសាស្ត្រ ចឹងមីងមកយល់ទាស់អីទេមីង?

អូចៈ ចាស ។

វណ្ណៈ៖ ចឹងមីងឈ្មោះ អីដែរ?

អូចៈ ធី អូច ។

វណ្ណៈ៖ មីងអាយុប៉ុន្មានហើយ?

អូចៈ អាយុ៤០ជាង ។

វណ្ណៈ៖ មិនមែន៤០ជាងទេ ៥០ជាងទេ?

អូចៈ ៥០ជាង ច្រឡំមាត់ អាយុ៥៥ ។

វណ្ណៈ៖ មីងមានឈ្មោះ ហៅក្រៅទេ?

អូចៈ អត់ ។

វណ្ណៈ៖ ប្តីមីងឈ្មោះ អីដែរ?

អូចៈ នួន មុខ ។

វណ្ណៈ៖ គាត់អាយុប្រហែលជាប៉ុន្មានហើយ?

អូចៈ អត់ដឹង អាយុ៧១ ។

វណ្ណៈ៖ មីងមានកូនទាំងអស់ប៉ុន្មាននាក់ទៅ?

អូចៈ មានកូន៨នាក់ ។

វណ្ណៈ៖ មានស្រីប៉ុន្មាន?

អូចៈ ស្រី៦នាក់ ។

វណ្ណៈ ចឹងមានប្រុសតែពីរទេ?

អូចៈ ចាស! ប្រុសពីរ ។

វណ្ណៈ ចឹងសព្វថ្ងៃមីងប្រកបមុខរបរអីដែរ?

អូចៈ មានអី ធ្វើស្រែចម្ការយើងហ្នឹង ។

វណ្ណៈ ចឹងស្រុកកំណើតនៅភូមិអី?

អូចៈ ស្រុកកំណើតនៅខេត្តមណ្ឌលគិរី ស្រុកកោះញែក ។

វណ្ណៈ ចឹងឥឡូវខ្ញុំសួរភូមិសិន?

អូចៈ ភូមិហ្នឹងភូមិកោះមីយើល ។

វណ្ណៈ ឃុំ?

អូចៈ ឃុំមីយើល ។

វណ្ណៈ ឃុំមីយើល?

អូចៈ ឃុំកោះញែក ខេត្តមណ្ឌលគិរី ។

វណ្ណៈ ចឹងឃុំកោះញែក ស្រុកកោះញែកដែរចឹង វាមានភូមិហើយបានឃុំហើយស្រុកហើយបាន ខេត្ត?

អូចៈ ភូមិមណ្ឌលគិរី ។

វណ្ណៈ អត់ទេ ខេត្តបានមណ្ឌលគិរី?

អូចៈ ខេត្តក្រចេះ ។

វណ្ណៈ អត់ទេ មីងនៅមណ្ឌលគិរី មីងនៅកោះញែក?

អូចៈ ចាស ។

វណ្ណៈ ឥឡូវភូមិមីយើល ចឹងបើឃុំកោះញែក ស្រុកកោះញែក ខេត្តមណ្ឌលគិរីចឹង?

អូចៈ ចាស ។

វណ្ណៈ ចឹងសព្វថ្ងៃមីងនៅភូមិអីដែរ?

អូចៈ ភូមិទួលប្រាសាទ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ។

វណ្ណៈ ខេត្តឧត្តរមានជ័យមីង?

អូចៈ ចាស ។

វណ្ណៈ ចឹងឪពុកមីង មីងនៅចាំដែល គាត់មានឈ្មោះអីដែរ?

អូចៈ អត់មានចាំទេ ខ្ញុំចេញមកតាំងពីតូចៗ ។

វណ្ណៈ: ចឹងមានចាំឈ្មោះ ម្តាយទេ?

អ៊ូចៈ ម្តាយក៏មិនចាំ ។

វណ្ណៈ: កាលពីតូចមីងមានបានរៀនសូត្រទេ?

អ៊ូចៈ អត់ទេ ។

វណ្ណៈ: ចឹងមីងនៅខាងកោះញែកចឹង មីងជាកូនកាត់ខ្មែរ?

អ៊ូចៈ កូនកាត់ខ្មែរ-លាវ ។

វណ្ណៈ: ចឹងមីងតាំងពីធំដឹងក្តីមក មីងនៅជួយធ្វើស្រែឪពុកម្តាយដែលឬយ៉ាងម៉េច យើងអាចដឹងថា យើងជួយធ្វើស្រែបានអាយុ៧ទៅ៨ឆ្នាំអីហ្នឹង?

អ៊ូចៈ អត់មានបានជួយ ខ្ញុំកើតមកធំដឹងក្តីប៉ុន ចៅនេះ គេចាប់ដាក់ក្នុងជួរមករហូតទាល់ឥឡូវ ។

វណ្ណៈ: អាយុប៉ុន្មានទៅ?

អ៊ូចៈ ខ្ញុំអាយុ១០ឆ្នាំ ។

វណ្ណៈ: ចឹងទើប១០ឆ្នាំ?

អ៊ូចៈ ចាស!គេចាប់ដាក់ក្នុងជួរ ។

វណ្ណៈ: ចឹងមីងមានដឹងថាឆ្នាំណាទេ គេចាប់ដាក់ក្នុងជួរ?

អ៊ូចៈ ខ្ញុំមិនដឹងឆ្នាំណាទេ ខ្ញុំមិនដឹងផង ចេះតែទៅតាមគេទៅ ។

វណ្ណៈ: ចឹងឆ្នាំកើតមានរដ្ឋប្រហារទម្លាក់សម្តេចសីហនុ មីងមានដឹងទេ?

អ៊ូចៈ ដឹងតើ ។

វណ្ណៈ: ចឹងឆ្នាំរដ្ឋប្រហារឆ្នាំ១៩៧០ហ្នឹង មីងនៅជាមួយឪពុកម្តាយឬមួយចេញហើយ?

អ៊ូចៈ អត់ទេ ខ្ញុំនៅក្នុងជួរហើយ ។

វណ្ណៈ: ចឹងចេញតាំងពីឆ្នាំ៧០មកចឹង?

អ៊ូចៈ ចាស ។

វណ្ណៈ: ចឹងកាលហ្នឹងមីងមកនៅក្នុងជួរហ្នឹងមីងមានដឹងថា មានទម្លាក់គ្រាប់បែកអីទេ អាមេរិចកាំង បើកយន្តហោះទម្លាក់គ្រាប់បែកមីងមានដឹងទេ?

អ៊ូចៈ អត់ទេ ។

វណ្ណៈ: ចឹងនៅខាងមណ្ឌលគិរីហ្នឹង អត់មានឃើញទម្លាក់ទេ?

អ៊ូចៈ អត់មានទេ កាលហ្នឹងនៅក្នុងព្រៃរហូត ដល់នៅក្នុងព្រៃទៅ កាលគេរំដោះភ្នំពេញហ្នឹង ។

វណ្ណៈ: បាទ!ឆ្នាំ៧៥?

អ៊ូចៈ ចាស!៧៥ កាលហ្នឹងគេការខ្ញុំនៅក្នុងជួរហ្នឹង ។

វណ្ណៈ	ចឹងឆ្នាំ៧៥មីងរៀបការហើយ?

អ៊ូចៈ	ចាស ។

វណ្ណៈ	ចឹងចាំមើលខ្ញុំចង់សួរមីងបន្តិចសិន មើលរដ្ឋប្រហារឆ្នាំ១៩៧០ហើយ មីងគេយកទៅក្នុងជួរកាលហ្នឹងមីងស្ម័គ្រចិត្តទៅដែរ?

អ៊ូចៈ	មិនស្ម័គ្រចិត្តទេ តែគេថាយកក្មេងៗទៅរៀនធ្វើពេទ្យធ្វើអី ចេះតែទៅតាមគេទៅគេចេញពីផ្ទះអស់ទៅនៅតែខ្ញុំម្នាក់ឯង ខ្ញុំទៅខាងណា ។

វណ្ណៈ	ចឹងកាលមីងចូលទៅដល់ដំបូងហ្នឹង មីងចូលនៅត្រឹមឃុំឬចូលទៅដល់ស្រុកឬចូលទៅដល់ណា?

អ៊ូចៈ	ចូលដល់ស្រុកភូមិឃុំគេហ្នឹងឯង ។

វណ្ណៈ	ចឹងចូលត្រឹមឃុំកោះញែកហ្នឹង?

អ៊ូចៈ	ចាស ។

វណ្ណៈ	កាលនៅហ្នឹងធ្វើអី?

អ៊ូចៈ	គេមានឲ្យធ្វើអីនៅកុមារតូចៗហ្នឹង ។

វណ្ណៈ	ចឹងកាលកុមារតូចៗគេឲ្យធ្វើអីដែលគេឲ្យដាំទឹកឬមួយធ្វើអីឲ្យដាំស្លឬឲ្យយើងនៅទំនេរសុទ្ធ?

អ៊ូចៈ	គេឲ្យយើងជួយស្រោចដាំណាំស្ពៃអីតាមសួនអីបន្តិចបន្តួចហ្នឹង ។

វណ្ណៈ	ចឹងក្រោយមកទៀតមីងមានដឹងថាមកនៅខេត្តអីទៀតមីងដឹងទេ?

អ៊ូចៈ	អត់ ។

វណ្ណៈ	ចឹងអត់មានមកដល់ខេត្តទេ នៅត្រឹមឃុំស្រុកហ្នឹង?

អ៊ូចៈ	ចាស ។

វណ្ណៈ	នៅត្រឹមស្រុកឬមួយយ៉ាងម៉េច?

អ៊ូចៈ	នៅត្រឹមស្រុកឃុំហ្នឹង ។

វណ្ណៈ	មានមនុស្សប៉ុន្មាននាក់ដែលកាលមីងនៅហ្នឹង?

អ៊ូចៈ	កាលនៅក្នុងជួរមានមនុស្សច្រើនហ្នឹងឯង រាប់រយរាប់ពាន់ ។

វណ្ណៈ	ចឹងនៅស្រុកហើយ?

អ៊ូចៈ	ចាស ។

វណ្ណៈ	ចឹងកាលហ្នឹងគណៈស្រុកអីមីងមានស្គាល់ទេ?

អ៊ូចៈ	អត់ស្គាល់ទេ ។

វណ្ណៈ	ចឹងគណៈតំបន់?

អ៊ូចៈ	អត់ដែរ ភ្លេចអស់ហើយ ។

វណ្ណៈ	ចឹងប្រធានគ្រប់គ្រងមីងឈ្មោះអីដែរ?

អូចៈ	ដឹងមិនស្គាល់ផង បែកពីគេយូរហើយ ។

វណ្ណៈ	ប្រធានមីងផ្ទាល់មិនស្គាល់ដែរ?

អូចៈ	វាបែកយូរហើយ ។

វណ្ណៈ	ចឹងពេលកម្លាំងចលនាវាយជាមួយ លន់ នល់ ហ្នឹងមីងមានដឹងទេ ច្បាំងគ្នារហូតដល់ឈ្នះចូល ភ្នំពេញអីហ្នឹង មីងមានដឹងទេ?

អូចៈ	ដឹងខ្លះអត់ខ្លះចុះវាភ្លេចភ្លាំងអស់ហើយ ។

វណ្ណៈ	តែពេលឈ្នះភ្នំពេញឆ្នាំ១៩៧៥ កាលហ្នឹងមីងថារៀបការហើយ?

អូចៈ	ការកូនមួយហើយ ។

វណ្ណៈ	ចឹងម៉េចបានមីងការក្នុងពេលហ្នឹង ព្រោះពូមិនទាន់ទៅដល់ហ្នឹងទេ?

អូចៈ	ទេ នេះខ្ញុំទើបយកក្រោយទេ ។

វណ្ណៈ	ចឹង?

អូចៈ	ប្ដីខ្ញុំមុន ។

វណ្ណៈ	កាលហ្នឹងរៀបការប៉ុន្មានគូរ?

អូចៈ	កាលហ្នឹងការ៨គូរនោះ ។

វណ្ណៈ	រៀបការពេលហ្នឹងមានឪពុកម្ដាយចូលរួមមានភ្លេងការអីដែរ?

អូចៈ	អត់ទេ ហៅប្រជុំយើងប្រកាស ដូចយើងធ្វើមេន្ទេញចឹង ។

វណ្ណៈ	ការកាលហ្នឹងហៅប្រជុំតែម្ដង?

អូចៈ	ចាស!អង្គុយតម្រង់ជួរដង្ហែរមួយសាលាហ្នឹង ។

វណ្ណៈ	ពេលរៀបការហ្នឹងមីងពេញចិត្តទេ?

អូចៈ	ខ្ញុំមានពេញចិត្តណាគ្រាន់គេចំអន់លេងក្មេងៗហ្នឹងណា ស្រាប់គេហៅដាក់ក្នុងជួរក្នុងសាលាហ្នឹង យំស្រស្រាក់អោបដើមចេក ពូខ្ញុំដេញវាយ តែដល់ការរួចគេឲ្យរួបដំណេកជាមួយគ្នា ខ្ញុំមានណារត់ បើមិនទាន់គ្រប់ការផងហ្នឹង ខ្ញុំមិនទាន់ពេញក្រមុំណាការហ្នឹង ។

វណ្ណៈ	ទាល់តែពេញហើយបានគេឲ្យការ មីងអាយុប្រហែលប៉ុន្មានពេលហ្នឹង?

អូចៈ	ខ្ញុំមិនទាន់គ្រប់ការផងហ្នឹងចាប់ការ ។

វណ្ណៈ	ចឹងមីងរត់?

អូចៈ	ខ្ញុំរត់គេកសាងប៉ុន្មានយប់ប៉ុន្មានថ្ងៃ គេធ្វើប្រវត្តិរូបហើយខាងប្រុសគេរត់ទៅទាហានគេវិញទៅ កាលហ្នឹង ។

វណ្ណៈ:	ឈ្មោះអីទៅគាត់?

អូចៈ	ប្ដីខ្ញុំឈ្មោះ នាង ។

វណ្ណៈ:	ចឹងការបានទៅជាមួយគ្នាទេចឹង?

អូចៈ	អត់ ។

វណ្ណៈ:	ចឹងក្រោយមកយ៉ាងម៉េចទៀតទៅ?

អូចៈ	ដល់ក្រោយគេឯងអប់រំយូរៗទៅ ខាងប្រុសគេហៅឲ្យមកវិញ ។

វណ្ណៈ:	ចឹងមកវិញបានជួបគ្នាទៅ?

អូចៈ	ចាស ។

វណ្ណៈ:	ចឹងប្ដីមីងឈ្មោះ នាង ហ្នឹងគាត់ធ្វើជាយោធា?

អូចៈ	ចាស! ធ្វើយោធា ។

វណ្ណៈ:	យោធានៅសមរភូមិមុខ?

អូចៈ	ចាស ។

វណ្ណៈ:	ចឹងពេលមីងការហើយ ខ្មែរក្រហមឈ្នះភ្នំពេញ មីងដែលមកភ្នំពេញទេ?

អូចៈ	អត់ទេ ។

វណ្ណៈ:	ចឹងគេឲ្យមីងនៅណាវិញ?

អូចៈ	មាននៅណារំដោះភ្នំពេញហ្នឹងគេឲ្យបែកគ្នារត់ចូលព្រៃរហូតទាល់ឥឡូវ ។

វណ្ណៈ:	មិនមែនទេ បែកភ្នំពេញរត់ចូលព្រៃហ្នឹងឆ្នាំ១៩៧៩ទេ?

អូចៈ	ចាស! ៧៩ ។

វណ្ណៈ:	ចាំមើលសម័យបីឆ្នាំ ចាំមើលខ្មែរក្រហមឈ្នះហើយឆ្នាំ១៩៧៥ ចឹងមីងថាការនៅពេលហ្នឹង ចឹងឥឡូវកូនមីងអាយុប៉ុន្មានហើយ?

អូចៈ	កូនខ្ញុំបងគេអាយុ៣០ហើយ៣០ជាងហើយ ។

វណ្ណៈ:	ចឹងពេលមីងការហើយគេមានបញ្ជូនមីងឲ្យទៅខាងណាទៀតទៅ?

អូចៈ	អត់មានទៅណាទេ នៅក្នុងឃុំស្រុកហ្នឹង ។

វណ្ណៈ:	គេឲ្យធ្វើអីទៅ?

អូចៈ	ធ្វើការងារនៅក្នុងឃ្លាំង កាលហ្នឹងគេឲ្យមើលចានឆ្នាំងរបស់ប្រជាជន ។

វណ្ណៈ:	ចឹងនៅខាងសេដ្ឋកិច្ច?

អូចៈ	ចាស! គេឲ្យនៅខាងសេដ្ឋកិច្ចនៅឃ្លាំងបើកឆ្នាំងបើចានឲ្យប្រជាជន ។

វណ្ណៈ:	ចឹងកាលហ្នឹងមានបើកអង្ករបើកអី កាលសម័យបីឆ្នាំមីងកុំច្រឡំជាមួយសម័យតាម៉ុក?

អូចៈ ចាស ។

វណ្ណៈ សម័យតាម៉ុក អាចមានចានឆ្នាំងបាន សម័យបីឆ្នាំគឺយើងហូបរួមសហករណ៍ទេ?

អូចៈ ចាស ។

វណ្ណៈ យើងមានតែខ្ទះធំៗ?

អូចៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងបើអង្ករបើកចំណីអាហារអីឲ្យទៅខាងណាវិញ?

អូចៈ ឲ្យដូចគេថាឲ្យទៅតាមតំបន់តាមឃុំតាមស្រុកមួយ ។

វណ្ណៈ ចឹងតាមស្រុកឃុំផ្សេងៗ?

អូចៈ ចាស ។

វណ្ណៈ ចឹងមកបើកគេបានមកអីមកបើកឬមួយគេយកឡានមកបើកឬយ៉ាងម៉េច?

អូចៈ ដឹកឡានតាមហ្នឹង ដឹកពីភ្នំពេញទៅមិនចូលក្រចេះ ចេញពីក្រចេះទៅមិនចូលមណ្ឌលគិរី ។

វណ្ណៈ ចឹងកាលហ្នឹងមីងបានមកដល់ខេត្តមណ្ឌលគិរីឬមួយនៅត្រឹមស្រុក?

អូចៈ នៅត្រឹមស្រុកហ្នឹង ។

វណ្ណៈ ស្រុកកោះញែកហ្នឹង?

អូចៈ ចាស ។

វណ្ណៈ ចឹងកន្លែងមីងនៅស្រុកចាំបើកអង្ករនៅខាងសេដ្ឋកិច្ចហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

អូចៈ ចុះគេហៅមន្ទីរណា ក្នុងមន្ទីរមួយៗមានរាប់រយខ្ទង់ដុះ ។

វណ្ណៈ គេហៅមន្ទីរអីទៅគេហៅមន្ទីរលេខប៉ុន្មានមន្ទីរហ្នឹង?

អូចៈ មិនដឹងជាមន្ទីរលេខប៉ុន្មានទេ ខ្ញុំមិនបានស្គាល់ផង ។

វណ្ណៈ ចឹងអត់មាននៅក្នុងកងពលដូចជាយោធាអីទេ?

អូចៈ អត់ទេ យោធានៅកន្លែងផ្សេង ពួកមន្ទីរនៅផ្សេង ។

វណ្ណៈ ចឹងមីងអត់មាននៅផ្នែកពេទ្យអីទេ?

អូចៈ ពេទ្យផ្សេង យើងនៅដូចថាកម្មករឥឡូវដូចជាកម្មកររោងចក្រអីហ្នឹង ។

វណ្ណៈ តែមីងមិននៅរោងចក្រទេ មីងនៅខាងសេដ្ឋកិច្ច?

អូចៈ នៅសេដ្ឋកិច្ចកម្មករគេ កន្លែងឃ្លាំងចានឆ្នាំង អង្ករសម្ភារ ។

វណ្ណៈ ចឹងប្រធានឃ្លាំងពីណាគេ?

អូចៈ ប្រធានឃ្លាំងមិនដឹងឈ្មោះអីទេ ខ្ញុំភ្លេចបាត់ហើយ ។

វណ្ណៈ ចឹងប្រធានឃ្លាំងហ្នឹងពីណាគេ?

អូចៈ ថាខ្ញុំភ្លេចឈ្មោះបាត់ហើយប្រធានឃ្លាំង ។

វណ្ណៈៈ ចឹងមីងអត់ស្គាល់គណៈស្រុកអីទេ បើមីងធ្វើការនៅស្រុកចាំបើកឃ្លាំងអីដែរ?

អូចៈ ភ្លេចបាត់ហើយយូរហើយ ។

វណ្ណៈៈ ចឹងមីងនៅកាន់ឃ្លាំងរហូតឬមួយគេមានផ្លាស់ប្តូរមីងទៅណាដែរ?

អូចៈ អត់ទេ នៅកន្លែងឃ្លាំង ។

វណ្ណៈៈ ចឹងនៅរហូតដល់វៀតណាមចូលតែម្តង?

អូចៈ ចាស!រហូតដល់វៀតណាមចូលហ្នឹង បែកគ្នាទៅ ។

វណ្ណៈៈ ចឹងកាលមីងនៅកន្លែងឃ្លាំងហ្នឹង មីងមានដឹងថាមានគេសម្លាប់មនុស្សចាប់មនុស្សអីដែលអត់មានទេ?

អូចៈ អ៊ូ!ជំនាន់នោះមិនបាច់និយាយទេ បើនៅកន្លែងមន្ទីរពួកខ្ញុំហ្នឹង គេចាប់មកដឹកមកពីភ្នំពេញមកចូលក្រចេះ ដឹកទាំងឡានៗដាក់កន្លែងពួកខ្ញុំហ្នឹង ។

វណ្ណៈៈ សុទ្ធអ្នកទោស?

អូចៈ សុទ្ធអ្នកទោស ។

វណ្ណៈៈ ចឹងចាប់អ្នកធ្វើការឲ្យខ្មែរក្រហមដែលឬចាប់ប្រជាជន?

អូចៈ ចាប់ប្រជាជនយើងហ្នឹង ប្រជាជនចាស់ក្មេងៗប៉ុននេះៗអូស! ។

វណ្ណៈៈ គេចាប់បញ្ជូនទៅខាងណា?

អូចៈ គេចាប់មកចុះកន្លែងមន្ទីរពួកខ្ញុំហ្នឹង ដល់ស្អែកឡើងគេយកទៅព្រៃអស់រលីង ។

វណ្ណៈៈ យ៉ាងម៉េចបានគេយកទៅដាក់កន្លែងមីងសិន?

អូចៈ មិនដឹង ។

វណ្ណៈៈ ចឹងមានគុកដែរ?

អូចៈ អត់មានគុកទេ ។

វណ្ណៈៈ ចឹងសុទ្ធតែប្រជាជនទេ មិនមែនទ័ពអីទេ?

អូចៈ អត់ទេ ពីព្រោះមកពីណាពីណីក៏គេទុកមួយយប់ត្រង់ហ្នឹងសិន ព្រឹកឡើងបានគេយកចេញទៅណាទៅណី ដឹកមកទាំងឡានៗយើងឃើញម្តងអាណិតណាស់ មិនថាកូនគេមិនថាម៉ែគេមិនថាឪគេទេ ដាក់មួយឡានៗឡើងជាន់គ្នាណែន ។

វណ្ណៈៈ ឆ្នាំណាទៅមីង មីងមានចាំឆ្នាំទេ បែកឆ្នាំ៧៥ហ្នឹងបានប្រហែលជាប៉ុន្មានឆ្នាំ?

អូចៈ ប៉ុន្មានឆ្នាំទេយូរដែរ ។

វណ្ណៈៈ ចឹងដូចថាចូលរបបហ្នឹងពីរទៅបីឆ្នាំបានមានដឹកមក?

អូចៈ ចាស ។

វណ្ណៈ ចឹងដឹកមកចឹងហ្នឹងអ្នកទាំងអស់ហ្នឹងគេយកទៅសម្លាប់ឬមួយគេយកទៅណា?

អូចៈ គេយកទៅសម្លាប់ ។

វណ្ណៈ ម៉េចបានមីងដឹងថា យកទៅសម្លាប់?

អូចៈ ម៉េចថាមិនដឹងបើនៅត្រង់ហ្នឹងហើយ មិនដឹង បើក្បាលដូចក្បាលដាំតែអុងហើយ ។

វណ្ណៈ ចឹងកាលជំនាន់ហ្នឹង មីងគ្រាន់តែដឹងថាគេដឹកយកទៅសម្លាប់ឬមួយមីងឃើញផ្ទាល់ដែរ?

អូចៈ ចុះបើកន្លែងគេសម្លាប់ភូមិហ្នឹងទៅនេះ ទៅមើលក្បាលមនុស្សឡើងរងៀករងោគនោះមិនដឹងជាយកទៅណាទេ បើសម្លាប់ចោលហើយឡានមក និយាយពីត្រនាប់ជើងវាប្រមូលដាក់ក្នុងឡានយកមកចាក់ទុកនៅខ្ទាំងហ្នឹង ។

វណ្ណៈ ចឹងមីងបានទៅឃើញសាកសពគេសម្លាប់ចោលហ្នឹងដែរ?

អូចៈ ឃើញតើ ។

វណ្ណៈ ចឹងយើងចូលទៅមើលបានដែរចឹង?

អូចៈ ឥឡូវនេះ ។

វណ្ណៈ អត់ទេ ចង់និយាយកាលពីជំនាន់មីងហ្នឹង?

អូចៈ ចូលបានតើ ។

វណ្ណៈ ចឹងគេអត់មានហាមឃាត់ខ្លាចបែលការណ៍អីទេ?

អូចៈ ទេ បើក្បាលខ្លា ឆ្អែវាអូសឡើងក្បាលមិនដឹងជាយកទៅណា ។

វណ្ណៈ ចឹងកន្លែងសម្លាប់ហ្នឹងគេហៅព្រៃអីភូមិអីឃុំអីទៅ?

អូចៈ មិនដឹងគេហៅព្រៃអីទេ គេដាក់ខាងនោះឃុំស្រុកអីហ្នឹង មិនឆ្ងាយអីទេ ។

វណ្ណៈ ចឹងមានឆ្កែអូសឬក៏ខ្លាអូស?

អូចៈ ឆ្កែព្រៃ ខ្លាអីវាអូស គេជីករណ្តៅធំៗដាក់ មួយរណ្តៅមាន១០ទៅ២០នាក់អីចឹង មានលុបជិតណា វាស្អុយទៅមិនខ្លាមិនឆ្កែអូសក្បាលមិនដឹងជាយកទៅណាទេ ឃើញតែលលាហ្នឹង ។

វណ្ណៈ ចឹងខោអាវគេដឹកយកមកវិញ?

អូចៈ គេយកតែត្រនាប់ជើងទេ គេយកមកឡើងកន្ទះឡាននោះ យកមកចាក់នៅឃ្លាំង ។

វណ្ណៈ មីងខស្សាហ៍ឃើញគេដឹកទៅញឹកញាប់ដែលឬមួយយូរៗឃើញម្តង?

អូចៈ ជួនកាលពីរបីថ្ងៃមកពីរបីឡាន ពីរបីថ្ងៃមកពីរបីឡាន តែមួយឡានៗណែនៗនោះទាំងប្រុសទាំងស្រីទាំងចាស់ទាំងទំសក់ស្កូវបាក់ធ្មេញឃើញទាំងអស់ហ្នឹង ។

វណ្ណៈ ចឹងក្នុងមួយឡានមីងគិតមើលមាន២០នាក់៣០នាក់?

អ៊ូចះ	អូ!មិនមែន២០ទេ ចុះឡានយើងអាធំៗដាក់ឡើងជាន់គ្នាញ៉ុកណែនតែម្តងណា ។

វណ្ណៈ	ចឹងទាំងក្មេងទាំងចាស់?

អ៊ូចះ	ចាស!ទាំងក្មេងទាំងចាស់ យំរងិរងក់ឃើញចឹង ។

វណ្ណៈ	ចឹងឃើញខ្លះយំ?

អ៊ូចះ	ចុះបើកូនៗវាណែនវាមិនយំខ្លះឃ្លានបាយឃ្លានទឹក ឃើញអាណោចអាធម្មមែនទែន ។

វណ្ណៈ	ចឹងពេលយកមកដាក់កន្លែងមីងមានឲ្យបាយទឹកហូបទេ?

អ៊ូចះ	មានពីណាហ៊ានដាក់ គេទុកឡានចោលហ្នឹង ព្រឹកឡើងគេដឹកទៅណាបាត់ ។

វណ្ណៈ	ចឹងគេដាក់ក្នុងឡានទាំងយប់ហ្នឹង អត់មានឲ្យចុះសម្រាកស្រួលបួលទេ?

អ៊ូចះ	អត់!បើថាអ្នកទោសខ្លាំងបានគេយកចុះ គេចងតាមដើមឈើចឹង ។

វណ្ណៈ	ចឹងមីងបានឃើញគេចងផ្ទាល់ភ្នែក?

អ៊ូចះ	ចាស!ចុះកន្លែងមន្ទីរពួកខ្ញុំហ្នឹង មន្ទីរឃ្លាំង ។

វណ្ណៈ	គេហៅមន្ទីរអីគេ?

អ៊ូចះ	គេហៅមន្ទីរអីទេ បើឡានចេញពីក្រចេះមិនផ្លូវហ្នឹង ។

វណ្ណៈ	ចឹងចេញពីក្រចេះទៅដល់មណ្ឌលគិរី?

អ៊ូចះ	ចាស ។

វណ្ណៈ	ចឹងយ៉ាងម៉េចបានមីងដឹងថាគេដឹកយកពីភ្នំពេញទៅ?

អ៊ូចះ	ចុះវាមិនចេញពីនោះ ។

វណ្ណៈ	ចឹងប្រជាជនទាំងអស់ហ្នឹងមិនមែនអ្នកមណ្ឌលគិរីចឹង?

អ៊ូចះ	អត់ទេ ។

វណ្ណៈ	ចឹងមានអ្នកថ្មីអ្នក១៧មេសាអីហ្នឹង?

អ៊ូចះ	បែបចឹងដឹង ។

វណ្ណៈ	ចឹងកាលហ្នឹងមីងមិនបានចាំឆ្នាំ ចឹងពេលហ្នឹងប៉ុន្មានឆ្នាំក្រោយមកវៀតណាមចូលឬជិតវៀតណាមចូលហ្នឹង?

អ៊ូចះ	អាជិតវៀតណាមចូលហ្នឹងឯង ។

វណ្ណៈ	ចឹងជិតវៀតណាមចូល?

អ៊ូចះ	ចាស ។

វណ្ណៈ	ចឹងប្រហែលជាឆ្នាំ៧៧-៧៨ហ្នឹង?

អ៊ូចៈ	ប្រហែលជា៧/៨ហ្នឹង អាហ្នឹងដឹកខ្លាំងណាស់អ្នកទោស បើខ្ញុំឃើញផ្ទាល់ភ្នែក បើថាមិនឃើញខ្ញុំអត់ចេះនិយាយទេ ។

វណ្ណៈ	ចឹងមីងមានចិត្តអាណិតទេ ពេលហ្នឹង?

អ៊ូចៈ	អាណិតហើយតែមិនដឹងធ្វើយ៉ាងម៉េច ។

វណ្ណៈ	ចឹងអ្នកដែលដឹកអ្នកដែលគេយកទៅសម្លាប់ហ្នឹង មីងមានដែលស្គាល់គេទេ?

អ៊ូចៈ	អត់ទេ ។

វណ្ណៈ	មិនដឹងជាយោធាមកពីខាងណាទេ?

អ៊ូចៈ	ដឹងគេមកពីខាងណា ។

វណ្ណៈ	ចឹងកន្លែងមីងមានគ្នារាប់រយនាក់ចឹងមានបាត់ខ្លួនខ្លះទេ?

អ៊ូចៈ	អត់ទេ ។

វណ្ណៈ	ចឹងអត់មានអីទេ?

អ៊ូចៈ	អត់អីទេ ឃើញតែឡានដឹកមកពីក្នុងចូលទៅ ។

វណ្ណៈ	ចឹងមីងកាលហ្នឹងហូបចុកបានស្រួលដែរ?

អ៊ូចៈ	ចុះមានអីហូបចុកក្នុងមួយថ្ងៃបីដង ។

វណ្ណៈ	ចុះមីងមានដឹងថាប្រជាជនហូបចុកយ៉ាងម៉េចដែរ?

អ៊ូចៈ	ប្រជាជននៅតាមមន្ទីរខ្លះហូបវេទនាដែលណា ។

វណ្ណៈ	តាមសហករណ៍តាមភូមិ?

អ៊ូចៈ	ចាស ។

វណ្ណៈ	ចឹងមីងអត់មានដែលចុះទៅតាមភូមិអីមើលទេ?

អ៊ូចៈ	អត់ទេ ។

វណ្ណៈ	ចឹងក្នុងមួយថ្ងៃមានគេមកបើកអង្ករពីមីងប៉ុន្មានទៅ?

អ៊ូចៈ	នៅក្នុងមន្ទីរហ្នឹងជួនកាលគេមកបើកអង្ករ១០បេ២០បេ ។

វណ្ណៈ	ចឹងដឹកតែ១០ទៅ២០បេទេក្នុងមួយថ្ងៃ?

អ៊ូចៈ	ចាស ។

វណ្ណៈ	ចឹងមានម្ហូបទេ មានត្រីងៀតត្រីឆ្អើរអី?

អ៊ូចៈ	អត់មានទេ មានតែអង្ករ ។

វណ្ណៈ	ចឹងឲ្យតែអង្ករសុទ្ធ?

អ៊ូចៈ	ចាស ។

វណ្ណៈ	មកដឹករាល់ថ្ងៃ?

អូចៈ	មកដឹករាល់ថ្ងៃ ។

វណ្ណៈ	ចឹងមីងមានដឹងថាគេដឹកទៅណាទេ អង្គរប្អូនដប់បេហ្នឹង?

អូចៈ	ដឹកយកចេញទៅចែកប្រជាជនតាមមន្ទីរតាមអី ។

វណ្ណៈ	ចឹងប្តីមីងអ្នកស្រុកណាដែលកាលហ្នឹង?

អូចៈ	នៅស្រុកជាមួយគ្នាហ្នឹង គាត់ធ្វើកងទ័ព ។

វណ្ណៈ	ចឹងគាត់ធ្វើកងទ័ពបានមកផ្ទះរាល់ថ្ងៃឬមួយយូរៗបានមកម្តង?

អូចៈ	មួយខែគាត់មកម្តង គាត់នៅតែអីភ្នំពេញ ។

វណ្ណៈ	ចឹងគាត់ទៅធ្វើនៅភ្នំពេញនោះទេ?

អូចៈ	ចាស!គាត់ធ្វើទាហានការពារនៅភ្នំពេញ ។

វណ្ណៈ	ចឹងមីងនៅមណ្ឌលគិរី មីងនៅភ្នំពេញនោះហ្នឹង?

អូចៈ	ចុះកងទ័ពគេដើរ ។

វណ្ណៈ	ចឹងគាត់ទៅការពារឬមួយជានិរសាឲ្យពីណាទេបានទៅដល់ភ្នំពេញ?

អូចៈ	ហ្នឹងហើយធ្វើនិរសាឲ្យគេ តាមប្តីខ្ញុំនិយាយថាអ្នកភ្នំពេញ ។

វណ្ណៈ	ថានៅភ្នំពេញយ៉ាងម៉េច?

អូចៈ	ថាវាយកាប់សម្លាប់គ្នា ។

វណ្ណៈ	គាត់មាននិយាយចឹងដែរ?

អូចៈ	ចាស!ខ្លះយកបានទាំងមាសអីមក ហើយប្តីខ្ញុំយកក្រមាអីមក ថាយករបស់អ្នកទោសយកមកឲ្យប្រពន្ធកូនប្រើ ។

វណ្ណៈ	កាលហ្នឹងមីងមានកូនហើយ?

អូចៈ	ខ្ញុំមានកូនមួយកាលហ្នឹង ។

វណ្ណៈ	ប្តីមីងគាត់ទៅជាអង្គរក្សការពារឲ្យពីណាគេមីងមានដឹងទេ?

អូចៈ	ការពារឲ្យគេអ្នកធំ ។

វណ្ណៈ	អ្នកធំឈ្មោះអីទៅ?

អូចៈ	អត់ដឹង ខ្ញុំមិនដឹងទេ ។

វណ្ណៈ	តែឆ្ងាយសឹងអីហ្នឹង ម៉េចបានជាគាត់មួយខែបានមកម្តងកើត?

អូចៈ	គេឲ្យមកលេង ។

វណ្ណៈ	ចឹងពេលមកជិះឡានមកចឹង?

អូចៈ	ជិះឡាន ឡានទាហានឡានកង់ទ័ពហ្នឹង ។

វណ្ណៈ	ចឹងហេតុអីក្រោយមកទៀតបានមីងបែកបាក់ជាមួយគាត់?

អូចៈ	បែកបាក់កាលវៃកយួនចូលនេះ ។

វណ្ណៈ	គាត់ស្លាប់ឬក៏នៅរស់ឥឡូវ?

អូចៈ	ស្លាប់ហើយ ។

វណ្ណៈ	គាត់ស្លាប់មូលហេតុអីមីងមានដឹងទេ?

អូចៈ	ស្លាប់នេះកាលយើងវាយគ្នាត្រង់នេះ ស្លាប់ទាហានយើងឥឡូវ ។

វណ្ណៈ	ចឹងស្លាប់ឥឡូវៗប៉ុន្មានឆ្នាំហើយ?

អូចៈ	ស្លាប់ជាង១០ឆ្នាំ២០ហើយ ។

វណ្ណៈ	ចឹងមីងយកប្ដីក្រោយមានកូនប៉ុន្មានដែរ?

អូចៈ	បានកូនបួនសុទ្ធតែស្រីៗ ។

វណ្ណៈ	ចឹងមុនមានបួនដែរ?

អូចៈ	មុនបួន ។

វណ្ណៈ	ចឹងគ្រួសារមីងមុនប្រហែលជាគាត់ធ្វើធំដែរ?

អូចៈ	អត់ទេ ។

វណ្ណៈ	ចឹងគាត់បានធ្វើនិរសាបានឡើងទៅដល់ភ្នំពេញដែលហ្នឹង?

អូចៈ	ចុះតាមមេៗគេហៅ គេហៅស្នាណាទៅស្នាហ្នឹងពាក់កណ្ដាលយប់ក៏ទៅឲ្យតែគេហៅ ។

វណ្ណៈ	ចឹងកាលគាត់ទៅមណ្ឌលគិរីគាត់មានឡានតូចជិះទៅ?

អូចៈ	ឡានមេទាហានមេទ័ពគេហ្នឹង មានតូចខ្លះធំខ្លះ ឡានធំៗគេដឹកទ័ព ឡានមេៗចជិះឡានតូចៗ ។

វណ្ណៈ	ចឹងគាត់ជិះឡានអីទៅ?

អូចៈ	ជិះឡានជាមួយមេហ្នឹង ។

វណ្ណៈ	ចឹងទាល់តែមេមកដែលទេ មិនមែនយើងចង់មកបានរាល់ខែទេ?

អូចៈ	ទាល់តែមេគេនាំមកយើងមក ខែគេឡើងគេទៅទៀត ។

វណ្ណៈ	ចឹងកាលហ្នឹងនៅតែខាងមន្ទីរចាំតែបើកអង្ករឲ្យគេមកយកអីចឹងទៅ?

អូចៈ	ចាស ។

វណ្ណៈ	ចឹងពេលបើកគេមាននិយាយថា ២០បាវមិនគ្រាន់ទេ គេមានចង់បានថែមទៀតទេ?

អូចៈ	អត់ទេ ។

វណ្ណៈ	គេកំណត់ឬយ៉ាងម៉េច?

អូចៈ គេកំណត់ឲ្យប៉ុណ្ណឹង ។

វណ្ណៈ ចឹងមីងចេះកត់អីដែរ?

អូចៈ ទេ មានចេះអី គេអ្នកកត់ផ្សេង យើងគ្រាន់ជួយរាប់ជួយលើកគេ ។

វណ្ណៈ ចឹងមួយមន្ទីរមីងហ្នឹងមានគ្នាប៉ុន្មាននាក់ដែរ?

អូចៈ នៅមន្ទីរខ្ញុំមានមនុស្សប្រហែល១០នាក់ហ្នឹង សុទ្ធតែស្រីៗមានប្ដីអស់ ។

វណ្ណៈ ចឹងពេលវៀតណាមចូលយ៉ាងម៉េចបានជាមីងមិនរត់ទៅផ្ទះ ព្រោះអីបើរត់ទៅផ្ទះជិតតើ មីងនៅខេត្តហ្នឹងស្រាប់ត្រឹមខេត្តមណ្ឌលគិរីហើយមីងនៅត្រឹមស្រុកកោះញែក ហើយបើរត់មកដល់ឆាយសឹងអីហ្នឹង ហេតុអីបានជាមីងមិនរត់ទៅផ្ទះ?

អូចៈ រត់បានកន្លះខែដែរ គេថាវាយភ្នំពេញបែកហើយ គេហៅមកផ្ទះមានទៅណា អត់ទៅ ។

វណ្ណៈ ម៉េចបានជាមីងមិនចង់ទៅផ្ទះ?

អូចៈ ចូលក្នុងព្រៃរហូតទាល់ឥឡូវទៅ ។

វណ្ណៈ ចឹងរត់ចូលព្រៃទៅដល់ណាខ្លះទៅ?

អូចៈ មិនដឹងជាទៅដល់ណាដល់ណីក្នុងព្រៃហ្នឹង ។

វណ្ណៈ រត់បែកប្ដីរត់ជាមួយកូន?

អូចៈ រត់ពីរនាក់កូនតាមគេតាមឯងហ្នឹង ប្ដីមិនដឹងជាធ្លាក់ដល់ណា ធ្វើកងទ័ព ។

វណ្ណៈ ចឹងរត់ដល់ពេលណាបានជួបជុំប្ដីវិញទៅ?

អូចៈ មកដល់លើភ្នំដងរែកយើងហ្នឹងបានជួបគ្នា ។

វណ្ណៈ មកដល់ភ្នំដងរែកហ្នឹងគេហៅច្រកអីគេទៅ?

អូចៈ មិនដឹង ។

វណ្ណៈ ខ្លះគេនិយាយថានៅ១០០១-១០០៣អីចឹង?

អូចៈ ខ្ញុំនៅ១០០១ហ្នឹងឯង ។

វណ្ណៈ ចឹងមីងនៅ១០០១?

អូចៈ ចាស ។

វណ្ណៈ ចឹងមីងរត់ដល់១០០១នៅឆ្នាំណាមីង?

អូចៈ មិនដឹងជាឆ្នាំណាមកដល់១០០១ ខ្ញុំភ្លេចបាត់ហើយ ។

វណ្ណៈ ចឹងមីងមកជួបប្ដីនៅ១០០១ហ្នឹង?

អូចៈ ចាស ។

វណ្ណៈ ហើយបាននៅជាមួយគ្នាបន្តទៀតទៅ?

អ្នចះ	ចាស!ពេលនៅជាមួយគ្នាគេឲ្យធ្វើទាហានទៀត ដល់ឥឡូវបែកគ្នាទៀត និយាយរឿងហ្នឹងមិនចង់និយាយទេ នាំតែកំសត់ខ្លួនទេ ។

វណ្ណៈ	យ៉ាងម៉េចបានកំសត់មីង?

អ្នចះ	ចុះវាពិបាក វាវែ្ឆតឆ្អន់ហើយ ។

វណ្ណៈ	ចឹងកាលហ្នឹងមីងមានគ្រួសារមីងមានកូនហើយ ចឹងមីងមិនបានទៅកងដឹកជញ្ជូនទៀតទេ?

អ្នចះ	អត់ទេ ។

វណ្ណៈ	ចឹងគេឲ្យមីងធ្វើអី បិតចំរូងឬមួយធ្វើអី កាលនៅលើភ្នំនៅ១០០១?

អ្នចះ	បិតចំរូង ។

វណ្ណៈ	ចឹងបិតចំរូង?

អ្នចះ	ចាស ។

វណ្ណៈ	ក្នុងមួយថ្ងៃគេឲ្យបិតបានប៉ុន្មាន?

អ្នចះ	មួយថ្ងៃគេឲ្យបិត១០០ នរណាបិតមិនបានគេប្រជុំកសាងយើង កាប់ឬស្សីខ្លួនឯងបិតខ្លួនឯងកាលហ្នឹង ។

វណ្ណៈ	ចឹងមានកន្លែងខ្លះនិយាយថា បិតមួយថ្ងៃឲ្យបាន៣០០?

អ្នចះ	ដោយមនុស្សទេ ខ្លះបិតបាន៣០០ខ្លះបាន១០០ខ្លះបាន២០០ ។

វណ្ណៈ	ចឹងចំរូងគេធ្វើប្រវែងណាមីង?

អ្នចះ	ប្រវែងនេះ ។

វណ្ណៈ	ចឹងប្រហែលជាបីតឹកដែរ?

អ្នចះ	ចាស ។

វណ្ណៈ	ចឹងគេឲ្យបិតស្រួចចុងដើមយ៉ាងម៉េចមីងប្រាប់បន្តិចមើល?

អ្នចះ	បិតស្រួចចុងស្រួចដើម គេបិតបេះ ។

វណ្ណៈ	ចឹងមានប្រវែងប្រហែលជាបីតឹកដែរ?

អ្នចះ	ចាស ។

វណ្ណៈ	ចឹងមានគន្លាក់កណ្តាលទេ?

អ្នចះ	ចាស!គន្លាក់ហ្នឹងគេវាយដីទៅ ។

វណ្ណៈ	ចឹងពេលចំរូងធ្វើបានចឹងពីណាមកយកទៅ?

អ្នចះ	ពួកកងទ័ពយើងយកទៅដោតការពារនៅមុខ ។

វណ្ណៈ	ចឹងនៅ១០០១ហ្នឹងនៅកន្លែងហ្នឹងគេហៅកងពលប៉ុន្មានមីង?

អូចៈ មិនដឹងជាកងពលលេខប៉ុន្មានទេ ។

វណ្ណៈ ចឹងពីណាគ្រប់គ្រងនៅ១០០១ហ្នឹង?

អូចៈ តាមឿន ។

វណ្ណៈ តាមឿន ហ្នឹងប្រធានអីគេ?

អូចៈ ប្រធានកងពលគេហ្នឹង ។

វណ្ណៈ ចឹងមិនមែនតាសារឿនទេ?

អូចៈ តាសារឿនខ្ញុំមិនដែលស្គាល់ផង ។

វណ្ណៈ ប្រធានកងពលលេខប៉ុន្មាន?

អូចៈ មិនដឹងជាលេខប៉ុន្មានតាមឿន ហ្នឹង ។

វណ្ណៈ ចឹងពេលហ្នឹងមីងនៅសមរភូមិក្រោយប្រកក១០០១ហ្នឹង?

អូចៈ ចាស ។

វណ្ណៈ ចឹងប្រក១០០១ហ្នឹង បើតាមមីងដឹងថានៅម្តុំណា នៅក្នុងភូមិអីមីង កន្លែងដែលអាចថាចំណុចចំណាំគេហៅម្តុំអីដែរ ប្រក១០០១ហ្នឹងគេហៅប្រកអីគេ?

អូចៈ មិនដឹងជាប្រកអីម្តុំហ្នឹងនោះ ខ្ញុំមិនដឹងដែលមិនសូវស្គាល់ទេខ្ញុំ ខ្ញុំទើបមកថ្មីៗដែរ ។

វណ្ណៈ ចឹងមីងនៅ១០០១រហូតបុមានការផ្លាស់ផ្តូទៅនៅខាង១០០៣ជាមួយតាម៉ុកបុទៅខាងណាខាងណីទៀត ។

អូចៈ មកនៅ១០០៣ជាមួយតាម៉ុក នេះ ។

វណ្ណៈ ចឹងនៅ១០០១បានប៉ុន្មានឆ្នាំ?

អូចៈ នៅបានប៉ុន្មានឆ្នាំទេ បួនប្រាំឆ្នាំដឹង ។

វណ្ណៈ ចឹងមីងមានដឹងថាឆ្នាំណាមីងចេញទៅនៅ១០០៣វិញ?

អូចៈ មិនដឹងជាឆ្នាំណាខ្ញុំមិនចេះចំណាំទេ ភ្លេចអស់ហើយនៅ១០០៣ហ្នឹង កាលហ្នឹងគេវាយទន្លេល្ពៅមិនដឹងជា៨០ប៉ុន្មានកាលហ្នឹងភ្លេចអស់ហើយ ។

វណ្ណៈ ចឹងមកនៅ១០០៣ជាមួយតាម៉ុក វិញ?

អូចៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងមីងមានដឹងថា សុន សេន នៅ១០០១មីងមានដឹងទេ កាលហ្នឹងតាសុន សេន នៅ១០០១តាម៉ុក នៅ១០០៣គេបែកគ្នាចឹង?

អូចៈ តាសុន សេន ខ្ញុំស្គាល់តើ ។

វណ្ណៈ ចឹងតាសុន សេន គាត់គ្រប់គ្រងនៅ១០០១ហ្នឹងមិនមែនទេ?

អ៊ូចៈ ចាស! នៅ១០០១ ខ្ញុំទៅរៀនកន្លែងគាត់ ។

វណ្ណៈ ទៅរៀនខាងអីគេ?

អ៊ូចៈ រៀនសូត្រម្ដងៗ គេហៅទៅរៀន កាលហ្នឹងគាត់នៅលើភ្នំ ។

វណ្ណៈ រៀននិយាយពីអីខ្លះទៅ?

អ៊ូចៈ និយាយពីរឿងទ័ពរឿងកម្លាំង គេណែនាំយើង ។

វណ្ណៈ គេណែនាំថាយ៉ាងម៉េច?

អ៊ូចៈ មិនដឹងនិយាយអីខ្លះទេ ។

វណ្ណៈ គេមិនមែនហៅតែមីងទេ គេហៅទាំងអស់គ្នា?

អ៊ូចៈ គេហៅតាមក្រុមមួយៗ ដូចយើងគេចាត់តាំងឲ្យធ្វើប្រធានធ្វើអនុមេក្រុមអីចឹងណាស់ ។

វណ្ណៈ ចឹងមីងបានធ្វើត្រឹមប្រធានក្រុមអីដែរ?

អ៊ូចៈ ធ្វើតើ ។

វណ្ណៈ ធ្វើត្រឹមណា?

អ៊ូចៈ ធ្វើត្រឹមប្រធានក្រុម ។

វណ្ណៈ ចឹងប្រធានក្រុម១០០១ហ្នឹងគេឲ្យមីងធ្វើអី?

អ៊ូចៈ មានធ្វើអីទេ គេឲ្យដឹកនាំប្រជាជនបិតចំរូងអីតែប៉ុណ្ណឹង ដឹកនាំបើអង្ករបើកស្ពៃៗឲ្យប្រជាជន ។

វណ្ណៈ ចឹងកាលហ្នឹងចំណីអាហារអីអត់មានខ្វះខាតទេ?

អ៊ូចៈ អត់ទេ ជំនាន់ហ្នឹង ។

វណ្ណៈ ចឹងបើកឲ្យគ្រប់គ្រាន់?

អ៊ូចៈ បើកប្រហុកអំបិល ស្ករប៊ីចេង ត្រីខ មីទាំងឡាំងៗ ។

វណ្ណៈ ចឹងពេលមកនៅជាមួយតាម៉ុក តាម៉ុកឲ្យធ្វើអីដែរ?

អ៊ូចៈ មានធ្វើអីគេឲ្យដឹកជញ្ជូនគ្រាប់ ។

វណ្ណៈ មីងមានកូនមានចៅហើយគេដឹកជញ្ជូនគ្រាប់ទៀត?

អ៊ូចៈ ជញ្ជូនកូនមួយកូនពីរទៅហើយ នេះចុះភ្នំនេះ ។

វណ្ណៈ ចឹងដល់ជញ្ជូនគ្រាប់ចឹងមានវរៈមានកងពលហើយ?

អ៊ូចៈ កងពលតាពិន ស្គាល់តាពិនទេ ។

វណ្ណៈ មានឮឈ្មោះគាត់ដែរ ។

អ៊ូចៈ ខ្ញុំនៅជាមួយតាពិន ហ្នឹងតាពិន គាត់ប្រធាបកងពល ។

វណ្ណៈ តាពិន ហ្នឹងកងពលលេខប៉ុន្មាន?

អូចៈ	មិនដឹងជាលេខប៉ុន្មានទេ ឪវាបានស្គាល់ ។

វណ្ណៈ	ចឹងឈប់នៅជាមួយតាមឿនហើយ?

អូចៈ	ចាស ។

វណ្ណៈ	មកនៅជាមួយ តាពិន វិញ?

អូចៈ	ចាស! នៅជាមួយតាពិន នៅជាមួយតាម៉ុក ហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងមឹងជញ្ជូនគ្រាប់ហ្នឹងចុះមកដល់ណា?

អូចៈ	មកដល់ដីរាបយើងនេះ ។

វណ្ណៈ	ចឹងចុះពីលើភ្នំ?

អូចៈ	ចាស! ហើយគ្រាប់ធំៗនោះលើកពីរនាក់បានលីរួច ។

វណ្ណៈ	ចឹងមានជញ្ជូនទៅដល់ខេត្តឆ្ងាយៗដូចជាខេត្តកំពង់ធំអីនោះទេ?

អូចៈ	អត់ទេ ។

វណ្ណៈ	ចឹងជញ្ជូនចុះត្រឹមក្រោមហ្នឹងមានគេជញ្ជូនបន្តទៀតចឹង?

អូចៈ	មានទាហានគេទទួលទុក ជញ្ជូនចុះមកពីលើភ្នំនេះមានកងទ័ពគេនៅហ្នឹងយើងឈប់ត្រឹមហ្នឹង ។

វណ្ណៈ	ចឹងមឹងមកនៅ១០០៣មានជញ្ជូនគ្រាប់?

អូចៈ	ចាស ។

វណ្ណៈ	ចឹងនៅ១០០១មានជញ្ជូនគ្រាប់ទេ?

អូចៈ	អត់ ។

វណ្ណៈ	ចឹងនៅ១០០៣មឹងជញ្ជូនគ្រាប់បានរយៈពេលប៉ុន្មានដែរ?

អូចៈ	ជញ្ជូនបានពីរបីខែហ្នឹង ។

វណ្ណៈ	ចឹងមឹងថាគ្រាប់ធំៗសែងពីរនាក់ចឹងហើយចុះពីលើភ្នំចឹង អត់មានខ្លាចធ្លាក់ផ្ទុះអីទេ?

អូចៈ	អត់ទេ ។

វណ្ណៈ	គ្រាប់ធំៗចឹងគេចងខ្សែឬមួយយ៉ាងម៉េចគ្រាប់ធំចឹង?

អូចៈ	មានចងអីយើងលីស្នាយើងនេះ ចុះដណ្តើរភ្នំ ។

វណ្ណៈ	អត់មានខ្លាចធ្លាក់?

អូចៈ	អត់ទេ ។

វណ្ណៈ	ចឹងគ្រាប់បេយ៉ាងម៉េចទៅ គ្រាប់បេក្នុងម្នាក់ស្ពាយប៉ុន្មានទៅ?

អូចៈ	គ្រាប់បេស្ពាយខ្លះបីខ្លះបួន បើគេប្រុសស្ពាយច្រើន ។

វណ្ណៈ	ចឹងកូនទុកនៅលើភ្នំទៅ?

អ៊ូចៈ កូនទុកឲ្យបងៗ វាមើល ។

វណ្ណៈ ចឹងកាលហ្នឹងគ្រួសារមីងចុះទៅខាងណាវិញ?

អ៊ូចៈ គ្រួសារនៅវាយខាងមុន ។

វណ្ណៈ ចុះទៅខេត្តណាមានដឹងទេ?

អ៊ូចៈ អត់ដឹងទេ វាយតាមជាយដែនយើងហ្នឹង ។

វណ្ណៈ ព្រោះខ្លះឮថាទៅខាងកំពង់ចាម ខ្លះទៅខាងស្គន់ជិតភ្នំពេញ ចុះទៅដល់ហ្នឹង?

អ៊ូចៈ ចាស ។

វណ្ណៈ ចឹងកាលហ្នឹងតាសុន សេន មីងបានឃើញគាត់ផ្ទាល់ដែរ?

អ៊ូចៈ ឃើញ ។

វណ្ណៈ មានឃើញពីណាខ្លះនៅហ្នឹង អ្នកធំៗ?

អ៊ូចៈ មេទាហានគេ ឃើញតែគាត់ម្នាក់ទេ ឃើញកងការពារគេឡើងរាប់រយ ។

វណ្ណៈ ចឹងតាសុន សេន ចរិកគាត់យ៉ាងម៉េចដែរ?

អ៊ូចៈ មានយ៉ាងម៉េច សុភាពរាបសារតើ ពេលប្រជុំយើងម្ដងៗគាត់និយាយមួយៗ ។

វណ្ណៈ ចឹងតាម៉ុក ចរិកគាត់យ៉ាងម៉េចដែលតាម៉ុក?

អ៊ូចៈ តាម៉ុក កាចដែលតាម៉ុក ។

វណ្ណៈ ចឹងតាម៉ុក កាច?

អ៊ូចៈ ចាស ។

វណ្ណៈ គាត់កាចយ៉ាងម៉េច?

អ៊ូចៈ កាចជាមួយប្រជាជនកាចជាមួយទាហាន ។

វណ្ណៈ ចឹងខ្លះគេថាតាម៉ុក ចិត្តល្អសុំអីឲ្យហ្នឹង?

អ៊ូចៈ សុំទាល់តែយើងឆាប់យក បើយើងក្រទៅយកគាត់មិនឲ្យវិញ បើសុំបានហើយថយចេញឲ្យឆ្ងាយទៅ បើថានៅហ្នឹងគាត់ដកវិញឥឡូវ ។

វណ្ណៈ ចឹងក្រោយមកទៀតសង្គ្រាមវាយជាមួយទាហានរដ្ឋាភិបាលជាមួយវៀតណាមយូរៗទៅក្រោយមកទៀតវៀតណាមដកកងទ័ពចេញវិញ មីងមានដឹងថា វៀតណាមដកនៅឆ្នាំណាទេកាលហ្នឹង?

អ៊ូចៈ ខ្ញុំមិនដឹងទេ ។

វណ្ណៈ ចឹងមីងនៅលើភ្នំរហូតដល់ឆ្នាំណាបានចុះមកនៅខាងក្រោមនេះ?

អ៊ូចៈ មិនដឹងជា៧០ប៉ុន្មានទេ ។

វណ្ណៈ ចូល៩០ហើយលែង៧០ហើយ?

អូចៈ ចាស ។

វណ្ណៈ ចឹងមីងមានដឹងថា តាម៉ុក ធ្វើដូវចុះមកនៅឆ្នាំណា?

អូចៈ កាលតាម៉ុក ធ្វើដូវហ្នឹងខ្ញុំនៅលើនោះ តាម៉ុក គេចុះមកមុន ។

វណ្ណៈ ចឹងមីងចុះមកហ្នឹងមុនអ៊ុនតាក់ចូលមកឬចុះមកដំណាលអ៊ុនតាក់ កាលអ៊ុនតាក់មីងមានស្គាល់ ទេ អ៊ុនតាក់កាលបោះឆ្នោតឆ្នាំ១៩៩៣ហ្នឹង មីងចុះមកមុនហ្នឹងទៀតឬមួយយ៉ាងម៉េច?

អូចៈ ចុះក្រោយទេ ។

វណ្ណៈ ចឹងកាលអ៊ុនតាក់ចូលមកមីងចុះមកនៅ?

អូចៈ ចុះមកនេះនៅ ។

វណ្ណៈ យ៉ាងម៉េចបានជានៅយូរជាងគេ?

អូចៈ ខ្ញុំនៅលើភ្នំ ជាប់ទល់ដែនថៃ ។

វណ្ណៈ ចឹងឆ្នាំណាបានមីងចុះមក?

អូចៈ មិនដឹងជាឆ្នាំណាទេ ខ្ញុំភ្លេចអស់ហើយ ឪវាបានអ្នកចាំ ។

វណ្ណៈ ចឹងចុះមកដល់ដំបូងមកនៅភូមិហ្នឹងតែម្ដងឬមួយនៅណាសិនដំបូង?

អូចៈ ចុះមកដល់ដំបូងនៅនេះឯង ។

វណ្ណៈ ចឹងនៅហ្នឹង?

អូចៈ ចាស ។

វណ្ណៈ ចឹងនៅហ្នឹងគេដាក់កងពលលេខប៉ុន្មាន ដូចខ្លះគេហៅភូមិ៨៩ ខ្លះគេហៅភូមិអីនោះ?

អូចៈ ចាស! គេហៅភូមិ៨៩ ។

វណ្ណៈ ចឹងភូមិហ្នឹងគេហៅភូមិ៨៩?

អូចៈ ចាស ។

វណ្ណៈ ពូណារគប់គ្រងភូមិ៨៩?

អូចៈ តា០៥កាលពីមុន ។

វណ្ណៈ តា០៥តាសារឿន?

អូចៈ ចាស ។

វណ្ណៈ ឥឡូវគេហៅភូមិអី?

អូចៈ ភូមិទួលប្រាសាទ ។

វណ្ណៈ ចឹងសម័យតស៊ូគេហៅភូមិ៨៩?

អូចៈ ចាស ។

វណ្ណៈ ចឹងមីងមានដឹងថាហេតុអីបានគេដាក់លេខចឹង?

អូចៈ ខ្ញុំមិនដឹងដែរ ។

វណ្ណៈ ចឹងក្រោយមកទៀតគេចាប់តាប៉ុល ពត កាត់ទោសមីងមានដឹងទេកាលហ្នឹង?

អូចៈ អត់ដឹងទេ ។

វណ្ណៈ ចឹងពេលគេចាប់តាសារឿនអីនោះមីងមានដឹងទេ?

អូចៈ ដឹងដែលតើ ។

វណ្ណៈ យ៉ាងម៉េចបានគេចាប់គាត់?

អូចៈ ខ្ញុំអត់បានដឹងដែរ ខ្ញុំអត់បានចូលរួមប្រជុំជាមួយគេ ។

វណ្ណៈ ចឹងតាសារឿន មនុស្សគាត់យ៉ាងម៉េចដែរ?

អូចៈ តាសារឿន អត្តចរិកគាត់មានអីគាត់ ។

វណ្ណៈ ចឹងកាលធ្វើសង្គ្រាម មីងជួបការលំបាកទេ?

អូចៈ រឿងពិបាកៗណាស់ហើយ ស្ពាយកូនស្ពាយចៅ ស្ពាយអង្ករ រត់រហូត ។

វណ្ណៈ ចឹងក្រោយមកទៀត មីងមានដឹងថាពីណាបានបង្កើតឲ្យមានសមាហរណ៍កម្មចុះចូលជាមួយរដ្ឋាភិបាលអី?

អូចៈ អត់ដឹងផង ។

វណ្ណៈ ចឹងអត់បានដឹងថា តាជាតិ ជុំ តាកែវ អីទេ?

អូចៈ អត់ដឹង ។

វណ្ណៈ ចឹងពេលមីងចុះមកនៅនេះហើយ មីងមានរត់ចុះឡើងប៉ុន្មានដងទៀត បានយើងឈប់រត់នៅភូមិនេះបានតែម្ដង?

អូចៈ តែម្ដងទេ រត់តែម្ដងគេយកចុះមកពីលើភ្នំមកនៅនេះទៀត ។

វណ្ណៈ ចឹងកាលគេសមាហរណ៍កម្មគេដេញវាយតាម៉ុក ហើយខាងមេៗចូលជាមួយរដ្ឋាភិបាលហ្នឹងឆ្នាំណាមីងមានដឹងទេ?

អូចៈ មិនដឹងឆ្នាំណាទេ កាលហ្នឹងខ្ញុំភ្លេចអស់ហើយ ខ្ញុំមិនបានចាប់អារម្មណ៍ផង ។

វណ្ណៈ ចឹងអត់បានដឹងឆ្នាំទេ?

អូចៈ ចាស!ឮតែគេនិយាយ ។

វណ្ណៈ ចឹងបើយើងប្រៀបធៀបទៅសម័យយើងតស៊ូនិងសម័យឥឡូវហ្នឹង តើសម័យណាមួយរស់នៅស្រួលជាង?

អ្នចៈ	សម័យឥឡូវស្រួលជាង មានផ្លូវមានអី មានម៉ូតូមានអីជិះត្រឹមត្រូវ ។
វណ្ណៈ	ចឹងមីងបើយើងនិយាយពីជីភាពវិញ កាលសម័យពីដើមយើងរស់នៅជាមួយឪពុកម្ដាយយើង មិនទាន់ចូលចលនាតស៊ូអី កាលហ្នឹងមីងរស់នៅក្នុងជីវភាពលំបាកដែលឬមួយយ៉ាងម៉េច?
អ្នចៈ	វាពិបាកអត់មានអីហូប ។
វណ្ណៈ	ធ្វើស្រែមិនសូវបាន?
អ្នចៈ	ចាស!ធ្វើស្រែមិនបានហូបរួមទៀត ពិបាកហូបចុក ។
វណ្ណៈ	ចឹងជំនាន់ខ្មែរក្រហមបីឆ្នាំ?
អ្នចៈ	អត់កើតអីធម្មតាចឹង ។
វណ្ណៈ	ចឹងអត់អីទេ?
អ្នចៈ	ចាស ។
វណ្ណៈ	ចឹងសម័យឥឡូវនេះ?
អ្នចៈ	សម័យឥឡូវកាន់តែស្រួលទៀតហើយ ។
វណ្ណៈ	ចឹងឥឡូវមានវត្តអីសម្រាប់គោរពបូជាអីដែរ?
អ្នចៈ	មាន ។
វណ្ណៈ	មីងកាន់សាសនាអីដែរ?
អ្នចៈ	ខ្ញុំមានកាន់អីទេ ។
វណ្ណៈ	ចឹងមីងមិនដែលទៅវត្តទេ?
អ្នចៈ	ទៅដែលតើ ។
វណ្ណៈ	ទៅវត្តចឹងគេហៅថាសាសនាព្រះពុទ្ធ?
អ្នចៈ	ចាស ។
វណ្ណៈ	ចឹងមីងគិតថាទៅវត្តអីហ្នឹង មីងគិតថាមានប្រយោជន៍អីដែរ មីងគិតថាយើងចង់បានអីមកវិញហ្នឹង?
អ្នចៈ	មកវិញដឹងបានអី ។
វណ្ណៈ	ចឹងមីងទំលាមទំលាប់ប្រពៃណីពីដើមមកដល់ឥឡូវ មីងគិតថាមានខុសគ្នាយ៉ាងម៉េចដែរ ការស្លៀកពាក់អី?
អ្នចៈ	ពីមុនស្លៀកពាក់ខោអាវពណ៌ខ្មៅ ។
វណ្ណៈ	ចឹងមុនពណ៌ខ្មៅទៀតការស្លៀកពាក់ ជំនាន់សម្ដេចសីហនុ ការស្លៀកពាក់យ៉ាងម៉េចដែរ?
អ្នចៈ	ពាក់ខ្មៅ ។

វណ្ណៈ	អត់ទេ ស្លៀកពាក់ខ្មៅហ្នឹងជំនាន់ខ្មែរក្រហមទេ ខ្ញុំចង់សួរសម័យមុន?

អូចៈ	ស្លៀកពាក់ដូចឥឡូវ ។

វណ្ណៈ	ចឹងសម័យឥឡូវកូនចៅស្លៀកពាក់ទៅវត្តទៅវាំដូចពីដើមជំនាន់សម្តេចដែលឬមួយមានការខុសគ្នាយ៉ាងម៉េចដែរ?

អូចៈ	អត់ដូចទេ ។

វណ្ណៈ	ខុសយ៉ាងម៉េច?

អូចៈ	ខ្មែរយើងឥឡូវស្លៀកពាក់ខោអាវវាលខោអាវប៉ាក់ ខោកាបូយអីណា ។

វណ្ណៈ	ចឹងកាលសម័យខ្មែរក្រហមមានវត្តទេ?

អូចៈ	អត់មានទេ ។

វណ្ណៈ	ចឹងកាលសម័យសង្គ្រាមមីងមានដែលឃើញពីណាចាប់បានឈ្លើយសឹកទាហានយកមកធ្វើទារុណកម្មអីទេ?

អូចៈ	អត់ទេ ។

វណ្ណៈ	ចឹងមីងឃើញ ឃើញគេដឹកប្រជាជនយកទៅសម្លាប់ចោលទេ?

អូចៈ	ចាស!ជំនាន់នោះ ។

វណ្ណៈ	ចឹងមីងជីវភាពមីងរាល់ថ្ងៃហ្នឹងរស់នៅយ៉ាងម៉េចដែរ?

អូចៈ	មានអី ។

វណ្ណៈ	ចឹងនៅពេលធ្វើស្រែចម្ការក្នុងមួយឆ្នាំៗហ្នឹង មីងមានពិភាក្សាជាមួយគ្រួសារឬជាមួយកូនចៅយើងត្រូវពិភាក្សាថា យើងត្រូវធ្វើអីខ្លះ ចឹងបែបហ្នឹងមីងមានដែលពិភាក្សាទេ?

អូចៈ	ពិភាក្សាដែលតើ ពិភាក្សារឿងការងារថាត្រូវធ្វើអីៗចឹង ថាដាំណាំឡូងដាំសណ្តែកសៀងសណ្តែកដី ខ្លាចទៅមិនរួចយើងអត់មានអីធ្វើហ្នឹងគេ ដល់ចាស់ៗហើយធ្វើមិនរួចទេ ។

វណ្ណៈ	ចឹងមីងបើសិនជាមានសៀវភៅបង្រៀនពីប្រវត្តិសាស្ត្រជំនាន់បីឆ្នាំដែលយើងបានចងក្រងសរសេរមកហើយបញ្ចូលទៅក្នុងសាលាឲ្យក្មេងរៀន មីងគិតថាជាការល្អដែលអត់?

អូចៈ	ល្អ ។

វណ្ណៈ	ចឹងមីងគិតថា ការរៀនសូត្រមានចំណេះដឹងអាចជួយអីយើងបានខ្លះមីង មីងគិតថាមានផលប្រយោជន៍អីខ្លះដែរ?

អូចៈ	អត់ដឹង ។

វណ្ណៈ	ចឹងមីងមានកូនរៀនដល់ថ្នាក់ត្រឹមណាដែរ?

អូចៈ	ថ្នាក់ទី៧ ។

វណ្ណៈ	ចឹងបានត្រឹមទី៧ឈប់ហើយ?

អូចៈ	ចាស ។

វណ្ណៈ	ចឹងយ៉ាងម៉េចបានជាមិនឲ្យរៀនបន្ត?

អូចៈ	វាមិនចង់រៀន វាថាលំបាកការងាររម៉ែឪ វាថាលំបាកការងាររពេក ។

វណ្ណៈ	ចឹងមិនចង់រៀនបន្ត?

អូចៈ	ចាស ។

វណ្ណៈ	ចឹងមីងចំពោះអ្នកជិតខាងវិញ យើងរាប់អានគ្នាយ៉ាងម៉េចឥឡូវហ្នឹង?

អូចៈ	មានអីធម្មតា យើងរាប់អានគ្នាទៅវិញទៅមក ។

វណ្ណៈ	ចឹងមីងរាល់ថ្ងៃហ្នឹងមានខាងអង្គការឬសហគមន៍ណាចុះមកបង្ហាត់បង្រៀនជួយឲ្យយោបល់រឿងធ្វើស្រែចម្ការហ្នឹងមានទេ?

អូចៈ	មានតើ ។

វណ្ណៈ	ចឹងមីងមានធ្លាប់ចូលរួមប្រជុំទេ?

អូចៈ	ចូល ។

វណ្ណៈ	ចឹងមីងយល់យ៉ាងម៉េចដែលពេលមានគេមកជួយបង្រៀនរឿងដាំដុះអីហ្នឹង?

អូចៈ	បានគេមកពន្យល់យើង យើងរំភើបចិត្តហ្នឹងហើយ យើងសប្បាយនាំគ្នាខំធ្វើតាមគេ គេពន្យល់ឲ្យយើងដាំដំឡូងដាំអី ។

វណ្ណៈ	ចឹងដំឡូងដែលយើងធ្វើបានចឹង តើមានទីផ្សារស្រួលលក់ដែលទេ?

អូចៈ	គេមកទិញ ។

វណ្ណៈ	ចឹងយើងមិនបាច់យកលក់ដល់ផ្សារទេ?

អូចៈ	អត់ទេ ។

វណ្ណៈ	ចឹងដំឡូងមីងដាំបានច្រើនទេ?

អូចៈ	កាលហ្នឹងដាំបានមួយហាត់តែខូចអស់ ទឹកភ្លៀង ។

វណ្ណៈ	ចឹងអាហ្នឹងដាំបានតែដំឡូលទេ?

អូចៈ	ចាស ។

វណ្ណៈ	ចឹងបើមានទឹកភ្លៀងខូច?

អូចៈ	ចាស ។

វណ្ណៈ	ដំឡូងឆ្នាំហ្នឹងពុថា បានថ្លៃគ្រាន់បើដែរ?

អូចៈ	ដឹងដែលពុថាបាន៨០០ ។

វណ្ណៈ:	ចឹងកន្លែងខ្លះពុថាបាន៧០០ កន្លែងខ្លះពុថាបាន៦៩០ អីហ្នឹង ប៉ុនហ្នឹងបានថ្ងៃដែលតើ?

អូបៈ	ចាស ។

វណ្ណៈ:	ចឹងបើសិនតម្លៃនៅថេរចឹងយើងនេះបានហើយ យើងមិនពិបាកទេ យើងអាចចំនិញបាន?

អូបៈ	ចាស!តែខ្ញុំវាបិបាកមនុស្សធ្វើ វាអត់មានកូនប្រុសហ្នឹងគេ កូនសុទ្ធតែស្រី ។

វណ្ណៈ:	ចឹងមីងរាល់ថ្ងៃមានបំណងចង់ទៅស្រុកកំណើតដែលបើមីងមិនដែលទៅសោះ តាំងពីចូលបដិវត្តមក?

អូបៈ	ចាស!ចង់ទៅដែលតែវាមិនមានលុយទៅ ។

វណ្ណៈ:	ចឹងទៅឥឡូវយ៉ាងច្រើនអស់២០ម៉ឺនហ្នឹងទៅមក ចឹងមីងអត់មានអីសួរមីងទៀត មីងមានអ៊ីចង់និយាយបន្ថែមទេ?

អូបៈ	អត់ទេ ។

វណ្ណៈ:	ចឹងខ្ញុំអរគុណមីងច្រើន ។

អូបៈ	ចាស ។

**ចប់**